ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# មតិស្វាគមន៍
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីលៀងអាហារស្វាគមន៍គណៈប្រតិភូធនាគារកណ្តាលថៃ
នៅសណ្ឋាគារ Le Meridienថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៤

សូមគោរព ៖

- ឯកឧត្តម PrasarnTrairatvorakulទេសាភិបាលធនាគារកណ្តាលថៃ ជាទីគោរពរាប់អាន!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងសមាជិកគណៈប្រតិភូទាំងអស់ជាទីស្នេហា!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា និងសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះ ឯកឧត្តម PrasarnTrairatvorakul ទេសាភិបាលធនាគារកណ្តាលថៃនិងគណៈប្រតិភូដែលអញ្ជើញមកបំពេញទស្សនកិច្ច និងចូលរួមកិច្ចប្រជុំទ្វេភាគីរវាងធនាគារកណ្តាលយើងទាំងពីរនៅខេត្តសៀមរាបនាពេលនេះ។

យើងខ្ញុំមានកិត្តិយសយ៉ាងខ្លាំងដែល ឯកឧត្តម និងគណៈប្រតិភូ បានឆ្លៀតពេលមមាញឹករបស់ខ្លួនមកចូលរួមកិច្ចប្រជុំទ្វេភាគីរបស់យើង ដើម្បីពង្រឹងនិងពង្រីកសហប្រតិបត្តិការមិត្តភាពរវាងស្ថាប័នទាំងពីរដែលយើងធ្លាប់មានជាប្រពៃណីពីយូរលង់ណាស់មកហើយ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម ដែលតែងតែផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេសនានាដល់ធនាគារជាតិនៃកម្ពុជា សំដៅរួមចំណែកអភិវឌ្ឍវិស័យធនាគារ ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់កម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម និងគណៈប្រតិភូទាំងអស់ សូមមានសុខភាពល្អ ទទួលបានជ័យជម្នះគ្រប់ភារកិច្ច និងស្នាក់នៅប្រទេសកម្ពុជាប្រកបដោយក្តីសោមនស្សរីករាយជាទីបំផុត ។ សូមអញ្ជើញលើកកែវឡើង ដើម្បីស្វាគមន៍ ។

**សូមអរគុណ**

ប្រអប់សំបុត្រលេខ ២៥, ឡូតិ៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧